00644021

E23/2

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 14 / 02 / 2011
ម៉ោង (Time/Heure): 15:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក-អជសដ

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១០

ភាគីដាក់ឯកសារ៖ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ បារាំង/បកប្រែជាភាសាខ្មែរ

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ៖ **សាធារណៈ / Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

## ចម្លើយតបទៅនឹងញត្តិរបស់លោក អៀង សារី សុំឲ្យបង្កើត សេចក្តីណែនាំស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

មេធាវី ពេជ អង្គ

មេធាវី Elisabeth SIMONNEAU-FORT

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

មេធាវី ជេត វណ្ណលី — មេធាវី ហុង គីមសួន

មេធាវី គីម ម៉េងឃី — មេធាវី ឡោ ជុនធី

មេធាវី ម៉ុច សុវណ្ណារី — មេធាវី ស៊ិន សុវ៉ន

មេធាវី សំ សុគង់ — មេធាវី វ៉ែន ពៅ

**ដាក់ជូន៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម ធូ មណី

មេធាវី ទី ស្រីនណា
មេធាវី Silke STUDZINSKY
មេធាវី Emmanuel ALTIT
មេធាវី Pascal AUBOIN
មេធាវី Olivier BAHOUGNE
មេធាវី Patrick BAUDOIN
មេធាវី Evelyne BOILEAU-BRANDOMIR
មេធាវី Philippe CANONNE
មេធាវី Annie DELAHAIE
មេធាវី Laure DESFORGES
មេធាវី Ferdinand DJAMMEN-NZEPA
មេធាវី Nicole DUMAS
មេធាវី Isabelle DURAND
មេធាវី Françoise GAUTRY
មេធាវី Marie GUIRAUD
មេធាវី Emmanuel JACOMY
មេធាវី Martine JACQUIN
មេធាវី Daniel LOSQ
មេធាវី Christine MARTINEAU
មេធាវី Madhev MOHAN
មេធាវី Barnabé NEKUIE
មេធាវី Lyma Thuy NGUYEN
មេធាវី Elizabeth RABESANDRATANA
មេធាវី Julien RIVET
មេធាវី Fabienne TRUSSES-NAPROUS
មេធាវី Nushin SARKARATI

<u>ចម្លងជូន</u>៖

**សហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Andrew CAYLEY
លោក យ៉េត ចរិយា
លោក William SMITH

**ជនត្រូវចោទ៖**
លោក ខៀវ សំផន
លោក អៀង សារី
លោកស្រី អៀង ធីរិទ្ធ
លោក នួន ជា

**សហមេធាវីការពារក្តី៖**
មេធាវី សុន អរុណ
មេធាវី Michiel PESTMAN
មេធាវី Victor KOPPE
មេធាវី អាង ឧត្តម
មេធាវី Michael G. KARNAVAS
មេធាវី ផាត់ ពៅស៊ាង
មេធាវី Diana Ellis
មេធាវី ស សុវាន
មេធាវី Jacques VERGÈS
មេធាវី Philippe GRÉCIANO

# សេចក្តីផ្តើម និងសំណើ

១. លោក អៀង សារី បានដាក់ញត្តិ[1]មួយជូនអង្គជំនុំជម្រះសាលាដំបូង ដែលមិនមែនជាលិខិតគតិយុត្តិ និងមិនអាចចាត់ទុកថាជាលិខិតគតិយុត្តិ។ ញត្តិដែលត្រូវបានដាក់មុនពេលបើកសវនាការដេញដោលនេះ អាចត្រូវបានវិភាគថាគ្រាន់តែជាសំណើក្រៅផ្លូវការមួយប៉ុណ្ណោះ និងមិនគិតកាលកំណត់អ្វីទាំងអស់។ ញត្តិនេះមិនអាចត្រូវបានវិភាគថាជាបណ្តឹង ឬជាសារណាឡើយ បើផ្អែកលើមាត្រា៨ នៃសេចក្តីណែនាំអនុវត្ត (អវតក/០១/២០០៧/វិសោធនកម្មលើកទី៥) ។ ទន្ទឹមនឹងគូសបញ្ជាក់ថាដើមបណ្តឹងរដ្ឋប្បវេណីមាន តួនាទីពេញលេញ និងទាំងស្រុងនៅចំពោះមុខ អ.វ.ត.ក. ដែលរូបគាត់ផ្ទាល់បានគាំទ្រនៅក្នុងសារណាឆ្លើយតប[2] របស់គាត់ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីការបស់សហចៅក្រមស៊ើបអង្កេតស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[3] លោក អៀង សារី បែរជាស្នើសុំឱ្យដាក់កម្រិតដល់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចាប់ពីពេលនេះតទៅ តាមរយៈសេចក្តីណែនាំមួយមុនពេលជំនុំជម្រះក្តី ក្រោមទម្រង់ជាសេចក្តីណែនាំអនុវត្តទៅវិញ។

២. អង្គជំនុំជម្រះសាលាដំបូងនឹងមើលឃើញច្បាស់អំពីលក្ខណៈផ្ទុយគ្នានៃសំណើបែបនេះ។ លើសពីនេះទៅទៀត លក្ខណៈអនីត្យានុកូលនៃសេចក្តីណែនាំបែបនេះ និងការប៉ះពាល់ដល់សិទ្ធិរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីបានស្តែងឡើងយ៉ាងច្បាស់ក្រឡែតតែម្តង។ តើ លោក អៀង សារី នឹងពិចារណាឃើញយ៉ាងដូចម្តេច អំពីសេចក្តីណែនាំស្តីពីការចូលរួម របស់មេធាវីការពារក្តីនៅក្នុងការជំនុំជម្រះក្តីនោះ? ភាគីទាំងអស់ទទួលបាននូវសមភាព និងស្វ័យភាពដូចគ្នា ហើយដែលត្រូវទទួលបាននូវការការពារដោយគ្មានរើសអើង[4]។ ជាក់ស្តែង

---

[1] ញត្តិរបស់លោក អៀង សារី សុំឱ្យបង្កើតសេចក្តីណែនាំស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ ឯកសារ E23។ (មិនទាន់ត្រូវបានបកប្រែជាភាសាបារាំង)។

[2] ចម្លើយតបរបស់ អៀង សារី ចំពោះបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងការបដិសេធដោយកសចស លើការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ D399/2/2។

[3] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានអាសយដ្ឋាននៅក្នុងខេត្តតាកែវ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D399/2/1។

[4] សូមមើល វិធាន ២១ ១) ក) នៃវិធានផ្ទៃក្នុង។

00644024



សំណើរបស់មេធាវីការពារក្តីគឺជាការមិនទទួលស្គាល់ ដោយចេតនា ឬអចេតនា ទៅលើនីតិវិធីជាធរមាន ស្របតាមប្រព័ន្ធច្បាប់ « Civil Law » ហើយបន្តចង់ផ្តល់សំអាងហេតុដោយភាន់ច្រឡំ តាមគោលការណ៍នៃប្រព័ន្ធច្បាប់ « Common Law » ដែលមិនត្រូវយកមកអនុវត្តនោះ។ ដើមបណ្តឹងរដ្ឋប្បវេណីដែលតំណាងដោយមេធាវីរបស់ខ្លួន មានសិទ្ធិចូលរួមនៅគ្រប់ដំណាក់កាលនៃនីតិវិធី នៅចំពោះមុខ អ.វ.ត.ក. ក្នុងនាមជាភាគីនៃរឿងក្តី ហើយក្នុងឋានៈនេះ ដើមបណ្តឹងរដ្ឋប្បវេណីទទួលបាននូវសិទ្ធិស្មើគ្នាទៅនឹងភាគីដទៃទៀត ដែលសិទ្ធិនេះត្រូវបានចែងដោយច្បាប់ និងដែលមិនត្រូវបានលើកយកមកចោទជាបញ្ហាឡើយ។

៣. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏មានកង្វល់ដូចជាលោក អៀង សារី ដែរ ក្នុងការចង់បាននូវការជំនុំជម្រះឱ្យបានឆាប់រហ័ស និងមានយុត្តិធម៌ ហើយសំណើបែបនេះមិនបានចូលរួមចំណែកដល់ការសម្រាលក្តីកង្វល់នេះទេ។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមិនអាចស្ថិតក្នុងសភាពគ្មានចម្លើយតបឡើយ បើទោះបីជាពួកគេយល់ឃើញយ៉ាងច្បាស់ក្រឡែតថាញត្តិនេះពុំមានមូលដ្ឋានសមស្របក៏ដោយ។ ដូច្នេះ មេធាវីសូមផ្តល់ការឆ្លើយតបយ៉ាងខ្លី។

៤. ជាបឋម ដើមបណ្តឹងរដ្ឋប្បវេណីចង់លើកឡើងជាចម្បងថា អង្គជំនុំជម្រះសាលាដំបូងគ្មានយុត្តាធិការក្នុងការសម្រេចលើញត្តិនេះឡើយ។

៥. ជាបន្តមកទៀត និងជាបន្ទាប់បន្សំ ដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឱ្យបដិសេធសំណើនេះចោលទាំងស្រុងតែម្តង។

### ក- មូលដ្ឋានទីមួយ: ជាចម្បង អង្គជំនុំជម្រះសាលាដំបូងគ្មានយុត្តាធិការ

៦. ច្បាស់ណាស់ថា អង្គជំនុំជម្រះសាលាដំបូងគ្មានយុត្តាធិការ ដើម្បីបង្កើតសេចក្តីណែនាំ ឬ

វិធានស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការជំនុំជម្រះក្តីឡើយ។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង បានកំណត់អំពីតួនាទី និងការចូលរួមរបស់ភាគីអន្តរាគមន៍ផ្សេងៗ ព្រមទាំងបានកំណត់ផងដែរអំពីមធ្យោបាយក្នុងការធ្វើវិសោធនកម្មវិធាន ដែលមានស្រាប់។ រាល់វិសោធនកម្មទាំងអស់គឺជាសមត្ថកិច្ចផ្តាច់មុខរបស់គណៈកម្មាធិការនីតិវិធីនិងវិធានផ្ទៃក្នុង និងរបស់សម័យប្រជុំពេញអង្គ។ ទោះជាក្នុងករណីណាក៏ដោយ មិនមានការផ្តល់យុត្តាធិការទៅឱ្យអង្គជំនុំជម្រះសាលាដំបូងឡើយ ហើយអង្គជំនុំជម្រះសាលាដំបូងត្រូវតែប្រកាសថាខ្លួនគ្មានយុត្តាធិការ។

**ខ). មូលដ្ឋានទីពីរៈ ជាករណីបន្ទាប់បន្សំ នៅលើអង្គច្បាប់**

៧. ដើម្បីឱ្យកាន់តែច្បាស់ ដើមបណ្តឹងរដ្ឋប្បវេណីសូមរៀបរាប់ឡើងវិញអំពីប្លង់នៃទឡ្ហីករណ៍របស់គូបដិបក្ខ។

**I. អំពីច្បាប់ជាធរមាន**

៨. ទាក់ទងនឹងសមភាពនៃមធ្យោបាយក្នុងការតទល់ក្តី មេធាវីការពារក្តីលោក អៀង សារី បានរៀបរាប់នូវអត្ថបទច្បាប់ជាធរមានមួយចំនួន សិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីក្នុងរយៈពេលសមស្រប តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងតួនាទីរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ វិធានទាំងអស់នេះត្រូវតែយកមកអនុវត្ត ដោយមិនអាចប្រកែកបាន។ ក៏ប៉ុន្តែ មេធាវីការពារក្តីលោក អៀង សារី មិនបានបង្ហាញថា តើវិធានទាំងនេះអាចយកមកគាំទ្រចំពោះទឡ្ហីករណ៍របស់ខ្លួនត្រង់ចំណុចណានោះឡើយ។

៩. ដើមបណ្តឹងរដ្ឋប្បវេណីសូមឱ្យមានការកត់សម្គាល់ថា គេអាចបន្ថែមទៅលើវិធានដែលចែងអំពីសិទ្ធិរបស់ភាគីទាំងនេះ នូវ៖

- វិធាន៩១ នៃវិធានផ្ទៃក្នុង ដែលចែងថា៖

  "១. អង្គជំនុំជម្រះសាលាដំបូងត្រូវស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញ ទៅតាមលំដាប់លំដោយដែលខ្លួនយល់ឃើញថាមានប្រយោជន៍"។

"២. ចៅក្រមអាចសួរសំណួរ ហើយសហព្រះរាជអាជ្ញា ភាគីទាំងអស់ និងមេធាវី ក៏ត្រូវបានអនុញ្ញាតឱ្យសួរសំណួរ ដោយមានការអនុញ្ញាតពីប្រធានអង្គជំនុំជម្រះសាលាដំបូង [...]"។

"៣. សហព្រះរាជអាជ្ញា ភាគីទាំងអស់ និង មេធាវី អាចជំទាស់ទៅនឹងការស្តាប់ចម្លើយសាក្សី ដែលកំពុងដំណើរការ ប្រសិនបើខ្លួនយល់ថាចម្លើយរបស់សាក្សីនោះមិនសម្តែងឱ្យឃើញការពិត។ នៅក្នុងករណីនេះ ប្រធានអង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចថា តើត្រូវស្តាប់ ឬមិនត្រូវស្តាប់ចម្លើយសាក្សីនេះ"។

ជាក់ស្តែង វិធានទាំងនេះអាចបង្ហាញអំពីសិទ្ធិស្មើគ្នាដែលភាគីទាំងអស់ទទួលបាននៅចំពោះមុខតុលាការ។

## II. អំពីឧឡារិកភាពរបស់មេធាវីការពារក្តីលោក អៀង សារី

១០. មេធាវីការពារក្តីលោក អៀង សារី អះអាងថាគោលការណ៍ ឬសេចក្តីណែនាំ "ដែលបញ្ជាក់អំពីតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី" អាចនឹងការពារសិទ្ធិរបស់លោក អៀង សារី និងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

### ក. អំពីសមភាពនៃមធ្យោបាយការពារក្តី

១១. មេធាវីការពារក្តីលោក អៀង សារី បានលើកឡើង[5]ជាបឋមនូវវិធាន២៣ ដែលបើតាមការអះអាងរបស់ខ្លួន នឹងធ្វើឱ្យដើមបណ្តឹងរដ្ឋប្បវេណីក្លាយជាព្រះរាជអាជ្ញាបន្ថែមម្នាក់ទៀត។ ការបកស្រាយនេះមិនទទួលស្គាល់ទាំងស្រុងនូវតួនាទី និងឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងការជំនុំជម្រះក្តី។ ជាក់ស្តែង ដើមបណ្តឹងរដ្ឋប្បវេណីមានតួនាទីលើកឡើងនូវអង្គហេតុដែលខ្លួនជាជនរងគ្រោះ រៀបរាប់នូវហេតុការណ៍ដែលខ្លួនបានជួបប្រទះ ការឈឺចាប់ និង

[5] ញត្តិរបស់លោក អៀង សារី សុំឱ្យបង្កើតសេចក្តីណែនាំស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ ឯកសារ E23 កថាខណ្ឌ០៧, ១០ និង ១២។

ផលវិបាកនៃអង្គហេតុមកលើពួកគេ ជាលក្ខណៈផ្ទាល់ខ្លួន។ ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីចូលរួមដោយស្វ័យភាពក្នុងការសម្តែងឱ្យឃើញនូវការពិត ដោយផ្តល់នូវសេចក្តីបំភ្លឺច្បាស់លាស់អំពីព្រឹត្តិការណ៍ និងធាតុផ្សំនៃភស្តុតាងដ៏ជឿជាក់មួយចំនួនដែលជាជំនួយដល់ការចោទប្រកាន់។ ក្នុងន័យនេះ និងផ្អែកលើទិដ្ឋភាពជាក់លាក់នេះ យើងអាចចាត់ទុកថាដើមបណ្តឹងរដ្ឋប្បវេណីចូលរួមចំណែកជួយដល់ការចោទប្រកាន់។

១២. គោលបំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺដើម្បីទទួលបានសំណងនៃព្យសនកម្មដែលខ្លួនបានទទួលរង ហើយវាឆ្លងកាត់ជាចាំបាច់ តាមរយៈការបង្ហាញអង្គហេតុ និងពិរុទ្ធភាពរបស់ជនជាប់ចោទចំពោះពួកគេ។ អាស្រ័យហេតុនេះ តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីខុសគ្នាស្រឡះពីតួនាទីរបស់សហព្រះរាជអាជ្ញា។

១៣. មេធាវីការពារក្តីលោក អៀង សារី[6] យោងដល់វិធាន២៣ ដោយចង្អុលបង្ហាញថា វិធាននេះតម្រូវឱ្យសហព្រះរាជអាជ្ញាមាន “តួនាទីតំណាងឱ្យផលប្រយោជន៍ទូទៅរបស់ជនរងគ្រោះ” ដែលដើមបណ្តឹងរដ្ឋប្បវេណីគ្រាន់តែមកគាំទ្រប៉ុណ្ណោះ។ នេះគឺជាការយល់ឃើញខុសគេខុសឯងពីវិធាននេះ។ តាមពិត ទោះបីជាសហព្រះរាជអាជ្ញាតំណាងឱ្យផលប្រយោជន៍សង្គមជាទូទៅ និងផលប្រយោជន៍របស់ជនរងគ្រោះទូទៅក្នុងន័យទូលាយក៏ដោយ ក៏វាមិនអាចជាការការពារផលប្រយោជន៍ដោយឡែករបស់ជនរងគ្រោះ ដែលត្រូវបានធានាផ្តាច់មុខដោយមេធាវីរបស់ពួកគេនោះឡើយ។

១៤. បន្ទាប់មកទៀត មេធាវីការពារក្តីលោក អៀង សារី ចាត់ទុកថា[7]ការបង្កើតមុខតំណែងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនដោះស្រាយបញ្ហាវិសមភាពនៃ

---

[6] ញត្តិរបស់លោក អៀង សារី សុំឱ្យបង្កើតសេចក្តីណែនាំស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ ឯកសារ E23 កថាខណ្ឌ១២ និង វិធាន ៨៧ ១) នៃវិធានផ្ទៃក្នុងអ.វ.ត.ក។

[7] ញត្តិរបស់លោក អៀង សារី សុំឱ្យបង្កើតសេចក្តីណែនាំស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ ឯកសារ E23 កថាខណ្ឌ០៦, ១០ និង ១១។

មធ្យោបាយតទល់ក្តី ដែលខ្លួនអះអាងថាជាជនរងគ្រោះ ដោយមិនបានបង្ហាញអំពី វិសមភាពនោះ។ លើចំណុចនេះ មេធាវីការពារក្តីលោក អៀង សារី ហាក់ដូចជាភ័យខ្លាច ចំនួនមេធាវីដែលខ្លួនត្រូវប្រឈមមុខ។ ការបង្កើតមុខតំណែងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានគោលបំណងអនុញ្ញាតឱ្យមានការសម្របសម្រួល និងការរៀប ចំអន្តរាគមន៍របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សំដៅធានាថាសិទ្ធិរបស់ពួកគេ ត្រូវបានគោរពយ៉ាងពេញលេញនៅក្នុងក្របខ័ណ្ឌនៃការជំនុំជម្រះក្តីរហូតដល់ចប់ យ៉ាងមានសារៈប្រយោជន៍ និង មានភាពរលូន។ វិធាន១២ស្ទួនពីរ ផ្តល់នូវសេចក្តីបញ្ជាក់គ្រប់គ្រាន់ ដោយចង្អុលបង្ហាញជាអាទិ៍ថា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវធ្វើការសម្របសម្រួលសកម្មភាពទាំងឡាយរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ភាសហការគ្នារវាងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអន្តរាគមន៍របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដូចមានចែងនៅក្នុងវិធាន១២ស្ទួនពីរ(៦) អាចធានាបាននូវការអនុវត្ត និងការតំណាងបានល្អប្រសើរនូវសិទ្ធិរបស់ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណី ទៅតាមទំនាក់ទំនងនៃទំនុកចិត្ត និងអង្គហេតុដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដឹងឮ និងចែករំលែកជាមួយនឹងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

១៥. ច្បាស់ណាស់ថា ការរួមផ្សំវិធាន១២ស្ទួនពីរ និងវិធាន៩១ អាចបញ្ជាក់យ៉ាងគ្រប់គ្រាន់អំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីដោយមិនចាំបាច់បន្ថែមអ្វីផ្សេងទៀតឡើយ។ ផ្ទុយទៅវិញ ប្រសិនបើសេចក្តីណែនាំត្រូវបានបង្កើតឡើង គឺដើមបណ្តឹងរដ្ឋប្បវេណីជាអ្នកទទួលរងនូវការប៉ះពាល់មិនអាចអនុគ្រោះបានដល់សិទ្ធិរបស់ខ្លួន ហើយនឹងត្រូវបានដកហូតសមភាពនៃមធ្យោបាយតទល់ក្តី ដោយរំលោភជាអាទិ៍លើវិធាន២១(១)(ក) នៃវិធានផ្ទៃក្នុង អ.វ.ត.ក។

## ខ. អំពីសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្នុងរយៈពេលសមស្រប

១៦. មេធាវីការពារក្តីលោក អៀង សារី បញ្ចេញនូវសម្មតិកម្មសុទ្ធសាធមួយថា ដើមបណ្តឹងរដ្ឋប្បវេណីរារាំងមិនឱ្យកូនក្តីខ្លួនទទួលបានសិទ្ធិនេះ តាមរយៈអាកប្បកិរិយារបស់ពួកគេ។ ក្រៅពីសម្មតិកម្មគ្មានអំណះអំណាងនេះ សូមរំឭកថាប្រធានអង្គជំនុំជម្រះសាលាដំបូងមាន

សិទ្ធិក្នុងការដឹកនាំសវនាការចំពោះភាគីទាំងអស់។ ការកែប្រែសំខាន់ៗត្រូវបានធ្វើឡើង នៅចន្លោះ សំណុំរឿង០០១ និងសំណុំរឿង០០២ ដើម្បីជៀសវាងនូវភាពច្រឡំច្របល់ និងការអូសបន្លាយពេលវេលា។ យើងគួរយោងទៅលើវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។ ភាគីនីមួយៗត្រូវព្យាយាមកុំបន្ថែមទម្ងន់ដល់សវនាការដោយឥតប្រយោជន៍ ហើយវិធាននេះយើងត្រូវតែគោរពទាំងអស់គ្នា។ ម្យ៉ាងវិញទៀត មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនមានអ្វីត្រូវទទួលមេរៀនពីមេធាវីការពារក្តីចំពោះបញ្ហានេះទេ ក៏ដូចជាបញ្ហាផ្សេងៗទៀតដែរ។

## គ. អំពីសំណើរបស់លោក អៀង សារី

១៧. ជាដំបូង លោក អៀង សារី បានព្យាយាមធ្វើការប្រៀបធៀបរវាងនីតិវិធីកម្ពុជាផ្សារភ្ជាប់នឹងនីតិវិធីរបស់ អ.វ.ត.ក និងនីតិវិធីនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ[8]។ ប៉ុន្តែច្បាស់ណាស់ អ.វ.ត.ក បានបង្កើតប្រព័ន្ធពិសេសមួយនៅក្នុងក្របខ័ណ្ឌយុត្តិធម៌អន្តរជាតិ ជាប្រព័ន្ធផ្តល់នូវឋានៈជាភាគីនៅក្នុងរឿងក្តីដល់ជនរងគ្រោះ ដោយយកលំនាំតាមប្រព័ន្ធច្បាប់បារាំង ដែលច្បាប់កម្ពុជាបានអនុម័តយកផងដែរ។ តុលាការព្រហ្មទណ្ឌអន្តរជាតិមិនមានប្រព័ន្ធបែបនេះទេ ដោយសារតែជនរងគ្រោះគ្រាន់តែជា "អ្នកចូលរួម" ហើយមានតែសិទ្ធិដ៏រឹតត្បិត យោងតាមលក្ខន្តិកៈក្រុងរ៉ូម។ នៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិគ្មានដើមបណ្តឹងរដ្ឋប្បវេណីទេ គឺមានតែជនរងគ្រោះប៉ុណ្ណោះ[9]។ ឋានៈទាំងពីរនេះមិនអាចច្រឡំគ្នាបានឡើយ។ ដូច្នេះឋានៈទាំងពីរនេះមិនអាចជាកម្មវត្ថុនៃវិធីសាស្ត្រប្រហាក់ប្រហែលដូចដែលមេធាវីការពារក្តីព្យាយាមចង់បាន ម្តងជាពីរដងនោះឡើយ។ អាស្រ័យហេតុនេះរឿងក្តី "រដ្ឋអាជ្ញា ទល់នឹង Katanga" មិនអាចយកមកធ្វើជាសំអាងបានឡើយ ពីព្រោះវាមិនមែនជាយុត្តិសាស្ត្រ។

១៨. បន្ទាប់មកទៀត មេធាវីការពារក្តីលោក អៀង សារី លើកឡើងអំពី "ការកម្រិត និងការរឹតត្បិត" ទៅលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ដើមបណ្តឹងរដ្ឋប្បវេណីខ្លះអាចត្រូវបាន

---

[8] ញត្តិរបស់លោក អៀង សារី សុំឱ្យបង្កើតសេចក្តីណែនាំស្តីពីការចូលរួមរបស់ដើមបណ្តឹង រដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ ឯកសារ E23 កថាខណ្ឌ១៧-២០។

[9] មាត្រា ៦៨ នៃ លក្ខន្តិកៈក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨។

ស្តាប់ចម្លើយយ៉ាងយូរ រហូតទាល់តែធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតមិនអាចផ្តល់សក្ខីកម្មបាន ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យមិនកំណត់។ ជាក់ស្តែង ជាឧទាហរណ៍ ឃ្លានីមួយៗដែលនិយាយដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវបានចាត់ទុកថាប៉ះពាល់ដល់ភាពឆាប់រហ័សនៃដំណើរការជំនុំជម្រះក្តី... (ចូរយើងគិតស្រមៃថា តើនឹងមានអ្វីកើតឡើង នៅពេលយើងស្តីបន្ទោសបែបនេះដល់មេធាវីការពារក្តីវិញនោះ?)។ តាមរយៈលក្ខណៈទូទៅ និងដោយសារតែវាព្យាយាមដកហូតពីភាគីតែមួយនូវសិទ្ធិក្នុងការនិយាយស្តីដែលគេមិនអាចប៉ះពាល់បាន ការកម្រិតដែលស្នើឡើងដោយមេធាវីការពារក្តី លោក អៀង សារី គឺជាការប៉ះពាល់យ៉ាងធ្ងន់ធ្ងរ និងមិនអាចអនុគ្រោះបានដល់សិទ្ធិរបស់ភាគីនោះ ដែលមិនអាចកើតមាននៅក្នុងការជំនុំជម្រះក្តីមិនលម្អៀង និងដោយយុត្តិធម៌បានឡើយ។

១៩. ជាចុងក្រោយ មេធាវីការពារក្តីលោក អៀង សារី ស្នើសុំ[10]ឲ្យមានសេចក្តីណែនាំអនុវត្តមួយរឹត ត្បិតសិទ្ធិរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសំណើអំពីទោស និងសួរសំណួរទៅកាន់សាក្សី អ្នកជំនាញ និងជនជាប់ចោទអំពីអត្តចរិតរបស់ជនជាប់ចោទ។ ក្រៅពីមិនអាចចេញជាសេចក្តីណែនាំអនុវត្តបានហើយនោះ សំណើបែបបនេះផ្ទុយនឹងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

២០. ចំពោះ<u>ទោស</u> ដើមបណ្តឹងរដ្ឋប្បវេណីសូមយោងទៅលើទឡ្ហីករណ៍ដែលខ្លួនបានគាំទ្រនៅក្នុងសំណើរួម ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៩ ក្នុងសំណុំរឿង០០១[11]។ ដើមបណ្តឹងរដ្ឋប្បវេណីក៏យោងផងដែរទៅលើមាត្រា៣(គ) និង១២(គ) នៃ "គោលការណ៍ជាសារវន្ត និងការ

---

[10] ញត្តិរបស់លោក អៀង សារី សុំឲ្យបង្កើតសេចក្តីណែនាំស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ ឯកសារ E23 កថាខណ្ឌ២១។

[11] ញត្តិរបស់លោក អៀង សារី សុំឲ្យបង្កើតសេចក្តីណែនាំស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ ឯកសារ E23 កថាខណ្ឌ១៥, សំណុំរឿង ០០១ ប្រឆាំងនឹង *កាំង ហ្គេកអ៊ាវ* សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឲ្យចេញសេចក្តីសម្រេចអំពីសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលបានកោះហៅ ឲ្យផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩ ឯកសារ E72/3 កថាខណ្ឌ២៦។

ណែនាំ ទាក់ទងនឹងសិទ្ធិនៃការធ្វើបណ្តឹង និងទាមទារសំណងរបស់ជនរងគ្រោះដោយសារការរំលោភជាក់ស្តែងនៃច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ”[12]។ អត្ថបទច្បាប់នេះផ្តល់យ៉ាងច្បាស់នូវលទ្ធភាពដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមចំណែកជាអាទិ៍ដល់ការកំណត់ទោសសមស្រប នៅពេលដែលទំនាក់ទំនងរវាងទោស និងទម្ងន់នៃអំពើដែលបានប្រព្រឹត្តទៅលើជនរងគ្រោះមានភាពច្បាស់លាស់។

២១. ចំពោះលទ្ធភាពក្នុងការតាំងសំណួរអំពីអត្តចរិតរបស់ជនជាប់ចោទ ទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានសម្រេចអំពីសិទ្ធិបែបនេះ នៅក្នុងសំណុំរឿង០០១ ដោយសេចក្តីសម្រេចចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៩[13] ក៏ដោយ ក៏គោលជំហរនេះផ្ទុយនឹងការអនុវត្តពីមុនរបស់អង្គជំនុំជម្រះសាលាដំបូង ហើយប្រហែលជាដោយសារតែមានសវនាការដេញដោលជាក់លាក់ច្រើនជ្រុលពេកជាប្រចាំ នៅក្នុងដំណើរការជំនុំជម្រះក្តីនេះ។ គោលជំហរដាច់ដោយឡែករបស់លោកចៅក្រម Jean-Marc LAVERGNE គូសបញ្ជាក់ពេលនោះថាសិទ្ធិដែលច្បាប់ធានាដល់ដើមបណ្តឹងរដ្ឋប្បវេណី ទោះជាក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឬវិធានផ្ទៃក្នុងរបស់អ.វ.ត.កក៏ដោយ បានផ្តល់ដល់ដើមបណ្តឹងរដ្ឋប្បវេណីនូវលទ្ធភាពក្នុងការធ្វើអន្តរាគមន៍លើគ្រប់បញ្ហាទាំងអស់ ដោយមិនបែងចែករវាងអង្គហេតុ និងអត្តចរិតឡើយ។ ការកម្រិតលើចំណុចនេះ នៅក្នុងសំណុំរឿង០០២ នឹងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិ

[12] គោលការណ៍ជាសារវន្ត និងការណែនាំទាក់ទងនឹងសិទ្ធិនៃការធ្វើបណ្តឹង និងទាមទារសំណងរបស់ជនរងគ្រោះដោយសារការរំលោភជាក់ស្តែងនៃច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ អនុម័ត និងប្រកាសឲ្យប្រើដោយសេចក្តីសម្រេចលេខ ៦០/១៤៧ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៥ របស់មហាសន្និបាតអង្គការសហប្រជាជាតិ។

[13] ញត្តិរបស់លោក អៀង សារី សុំឲ្យបង្កើតសេចក្តីណែនាំស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ ឯកសារ E23 កថាខណ្ឌ១០,១៥។ សំណុំរឿង ០០១ ប្រឆាំងនឹង *កាំង ហ្គេកអ៊ាវ* សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឲ្យចេញសេចក្តីសម្រេចអំពីសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលបានកោះហៅ ឲ្យផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩ ឯកសារ E72/3 កថាខណ្ឌ២៦។

របស់ដើមបណ្តឹងរដ្ឋប្បវេណី។ ប្រសិនបើបញ្ហានេះត្រូវបានពិភាក្សាដេញដោលម្តងទៀត ហើយសិទ្ធិនេះត្រូវបានជំទាស់នោះ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីប្រាកដជានឹងរក្សាជំហររបស់ខ្លួន ដើម្បីឱ្យមានការគោរពសិទ្ធិក្នុងការធ្វើអន្តរាគមន៍លើអត្តចរិតដែលដូចច្បាប់បានកំណត់។ លើសពីនេះទៅទៀត ប្រសិនបើជាញឹកញាប់ អង្គហេតុ និងអត្តចរិតមានភាពងាយស្រួលក្នុងការបែងចែកនោះ មានចំណុចស្រពិចស្រពិលដែលបញ្ហាណាមួយអាចត្រូវបានលាយឡំ ចូលគ្នា ឬត្រួតស៊ីគ្នា។

២២. ជាសរុប ការកម្រិត និងការរឹតត្បិតដែលស្នើដោយមេធាវីការពារក្តីលោក អៀង សារី គឺជាការប៉ះពាល់មិនអាចអនុគ្រោះបានដល់សិទ្ធិរបស់ភាគីមួយនៅក្នុងការជំនុំជម្រះក្តី ដោយជាន់ឈ្លីទាំងស្រុងទៅលើច្បាប់ និងវិធានជាធរមាននៅចំពោះមុខ អ.វ.ត.ក។ ម្យ៉ាងវិញទៀត ការកម្រិត និងការរឹតត្បិតបែបបនេះ គឺជាការប្រព្រឹត្តរើសអើងចំពោះភាគីផ្សេងៗ ដែលមិនអាចទទួលយកបាន។

## សេចក្តីសន្និដ្ឋាន

២៣. ជាចម្បង មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងប្រកាសថាខ្លួនគ្មានយុត្តាធិការ ដើម្បីសម្រេចលើញត្តិរបស់មេធាវីការពារក្តី អៀង សារី ឡើយ។

២៤. ជាបន្ទាប់បន្សំ ដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឱ្យបដិសេធញត្តិនេះចោលទាំងស្រុងតែម្តង ដោយសារមិនមានមូលដ្ឋានត្រឹមត្រូវ និងប៉ះពាល់មិនអាចអនុគ្រោះបានដល់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| 14/02/2011 | ពេជ អង្គ<br>សហមេធាវីនាំមុខ | ភ្នំពេញ | |

| | | | |
|---|---|---|---|
| 14/02/2011 | Elisabeth SIMONNEAU-FORT<br>សហមេធាវីនាំមុខ | ភ្នំពេញ | [signature] |

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១